ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១១៦
ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥
សាលដីកា
លេខ: ១០១
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម | [redacted] | ប្រធាន |
| ២-លោក | [redacted] | ចៅក្រមរបាយការណ៍ |
| ៣-លោក | [redacted] | ចៅក្រម |
| ៤-លោក | [redacted] | ចៅក្រម |
| ៥-លោកស្រី | [redacted] | ចៅក្រម |

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ឆាយ, បណ្តឹងសាទុក្ខលេខ១២៣ និងលេខ១២៤ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ របស់ឈ្មោ[redacted]ឯម និងឈ្មោះ [redacted]ចេង ចំពោះសាលដីកាលេខ០៦ក្រ.VI.ភស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ របស់សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ ដែលមាន៖

**-ជនជាប់ចោទ៖**

១.ឈ្មោះ [redacted] ចេង ភេទស្រី អាយុ៨៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិអង្គោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ



Scanned by CamScanner

ខេត្តកែប ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted]"ស" មានកូន០១នាក់ ទោសពីមុនគ្មាន។ (ជាអ្នកប្តឹងសាទុក្ខ)

២.ឈ្មោះ [redacted]ភេទស្រី អាយុ៧៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិអង្កោល ឃុំភ្នំលារ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ឪពុកឈ្មោះ[redacted]ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ[redacted] "ស" មានកូន០៤នាក់ ទោសពីមុនគ្មាន។

<u>**ជាប់ចោទពីបទ**</u> ៖ លក់អចលនវត្ថុអ្នកដទៃ ប្រព្រឹត្តនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា២៥៥ នៃច្បាប់ភូមិបាល។

៣.ឈ្មោះ [redacted] ឆាយ ហៅ ពែក ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរនេសាទ ទីកន្លែងកំណើតភូមិអង្កោល សង្កាត់អង្កោល ខណ្ឌដំណាក់ចង្អើរ ក្រុងកែប ទីលំនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ឪពុកឈ្មោះ [redacted]" ម្តាយឈ្មោះ[redacted] "រ" ប្រពន្ធឈ្មោះ[redacted] "រ" មានកូន០៣នាក់ ទោសពីមុនគ្មាន។ (ជាអ្នកប្តឹងសាទុក្ខ)

៤.ឈ្មោះ [redacted] ឯម ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ មុខរបរសមាជិកក្រុមប្រឹក្សាឃុំ ទីកន្លែងកំណើតនៅភូមិអង្កោល ឃុំភ្នំលារទី២ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ[redacted] "ស" ប្រពន្ធឈ្មោះ [redacted] "ស" មានកូន០៤នាក់ ទោសពីមុនគ្មាន។ (ជាអ្នកប្តឹងសាទុក្ខ)

<u>**ជាប់ចោទពីបទ**</u> ៖ ក្លែងបន្លំលិខិត ប្រព្រឹត្តនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧ បទល្មើសដែលមានចែង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា៦២៦ និងមាត្រា៦២៧ នៃក្រមព្រហ្មទណ្ឌ។

**-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ហៀវ ភេទស្រី អាយុ៧៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិត្រពាំងទៀល ឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ដែលបានប្រគល់សិទ្ធិជូនឈ្មោះ[redacted] ហ៊ិ ភេទប្រុស អាយុ២៧ឆ្នាំ មានទីលំនៅភូមិ៤ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ត្រូវជាចៅឱ្យមានសិទ្ធិតំណាងស្របច្បាប់។ (ជាចុងបណ្តឹងសាទុក្ខ)

✓ -លោ[redacted] តេជ ជាមេធាវី

<u>**អំពីអង្គហេតុ៖**</u>

ឈ្មោះ[redacted]ហៀវ បានកាន់កាប់ដីមួយកន្លែងស្ថិតនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប តាំងពីឆ្នាំ១៩៧៩ មក។ នៅក្នុងឆ្នាំ១៩៨៣ ឈ្មោះ[redacted]ហៀវ បានចាកចេញទៅរស់នៅ ... ឯស្រុកកំពង់ត្រាច ខេត្តកំពត បានឱ្យឈ្មោះ[redacted]ពិសិដ្ឋ ជាអ្នកជួយថែ និងបង្កបង្កើនផលប្រើដីនោះ...



Scanned by CamScanner

លុះមកដល់ឆ្នាំ២០០៧ ស្រាប់តែឈ្មោ[redacted]ចង និងឈ្មោះ [redacted] ហ៊ាន បានយកដីនោះលក់ទៅឲ្យឈ្មោះ[redacted]ឆាយ ហៅ ពែក និងបានឃុបឃិតគ្នាជាមួយឈ្មោ[redacted]ឯម ក្លែងមេដៃលោកមេភូមិអង្គោល ផ្ទេរសិទ្ធិកាន់កាប់ដីធ្លីចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧។

-បានឃើញសាលក្រមលេខ១១"ញ" ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសលើ៖

ក.ឈ្មោះ [redacted]ចង ភេទស្រី អាយុ៨៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិអង្គោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។ ឪពុកឈ្មោះ [redacted]" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ ដោយទោសនេះឲ្យព្យួរការអនុវត្តទាំងមូល យោងតាមមាត្រា ១០៤, មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។ ពីបទៈ លក់អចលនវត្ថុអ្នកដទៃ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុងមាត្រា២៥៥ នៃច្បាប់ភូមិបាល។

ខ.ឈ្មោះ [redacted]ហ៊ាន ភេទស្រីអាយុ៧៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិអង្គោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។ ឪពុកឈ្មោះ[redacted]" ម្តាយឈ្មោះ[redacted] "ស" ប្តីឈ្មោះ [redacted] "ស" មានកូន០៤នាក់ ទោសពីមុនគ្មាន។ បញ្ឈប់ការចោទប្រកាន់ពីបទៈ លក់អចលនវត្ថុអ្នកដទៃ តាមមាត្រា៧ ចំណុច១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

គ.ឈ្មោះ[redacted] ឆាយ ហៅ ពែក ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរនេសាទ ទីកន្លែងកំណើតភូមិអង្គោល សង្កាត់អង្គោល ខណ្ឌដំណាក់ចង្អើរ ក្រុងកែប។ ទីលំនៅបច្ចុប្បន្នភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted]" មានកូន០៣នាក់ ទោសពីមុនគ្មាន។

ឃ.ឈ្មោះ [redacted]ឯម ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ មុខរបរសមាជិកក្រុមប្រឹក្សាឃុំ ទីកន្លែងកំណើតភូមិអង្គោល ឃុំភ្នំលាវទី២ ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅបច្ចុប្បន្នភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោ[redacted]ស" មានកូន០៤នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ០២ឆ្នាំ។ ដោយទោសនេះឲ្យព្យួរការអនុវត្តទាំងមូល យោងតាមមាត្រា១០៤, មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ពីបទៈ ក្លែងបន្លំលិខិត ប្រព្រឹត្តនៅភូមិអង្គោល



Scanned by CamScanner

ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុងមាត្រា៦២៦ និងមាត្រា៦២៧ នៃក្រមព្រហ្មទណ្ឌ។

២-ឱ្យឈ្មោះ [redacted] ចេង, ឈ្មោះ [redacted] ឆាយ ហៅ ពែក និងឈ្មោះ [redacted] ឯម រួមគ្នាបង់សំណង និងជម្ងឺចិត្តជាប្រាក់មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀវ ក្នុងម្នាក់ៗចំនួន ៣.០០០.០០០រៀល "បីលានរៀល"។ បណ្តឹងទាមទារលើសពីនេះបដិសេធចោល។

៣-សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចេង, ឈ្មោះ [redacted] ឆាយ ហៅ ពែក និងឈ្មោះ [redacted] ឯម និងដើមបណ្តឹងរដ្ឋប្បវេណី។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៦ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ឆាយ, [redacted] ឯម និង [redacted] ចេង ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ១១"ញ" ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាដំបូង ខេត្តកំពត ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសាលដីកាលេខ០៦ក្រ.VI.ភស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ប្រកាសថាពាក្យបណ្តឹងឧទ្ធរណ៍លេខ៣៦ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ឆាយ, ឈ្មោះ [redacted] ឯម និងឈ្មោះ [redacted] ចេង មិនអាចទទួលយកបាន។

២-សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឆាយ ហៅ ពែក មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចេង បើកផ្លូវប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤, បណ្តឹងសាទុក្ខលេខ១២៣ និងលេខ១២៤ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ដែលប្តឹងមិនសុខចិត្ត នឹងសាលដីកាលេខ០៦ក្រ.VI.ភស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ របស់សភាព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-ជនជាប់ចោទបានប្តឹងឧទ្ធរណ៍ ដោយហួសរយៈពេលប្តឹងឧទ្ធរណ៍ ដោយយោងតាមមាត្រា៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីមូលហេតុបណ្តឹងឧទ្ធរណ៍ ដែលមិនអាច



Scanned by CamScanner

ទទួលយកបានកាលណាសាលាឧទ្ធរណ៍ យល់ឃើញថា បណ្តឹងឧទ្ធរណ៍បានធ្វើឡើងហួសរយៈពេលកំណត់។

-សាលដីកាព្រហ្មទណ្ឌលេខ០៦ក្រ.VI.ភស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ។

ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ:

១.ទទួលបណ្តឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted]ាយ បណ្តឹងសាទុក្ខលេខ១២៣ និងលេខ១២៤ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ឯម និងឈ្មោះ [redacted]ចេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៦ក្រ.VI.ភស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការ។

-ក្រឡាបញ្ជីអានសារណាការពារចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ របស់ឈ្មោ[redacted]ឆាយ។

-ក្រឡាបញ្ជីអានសារណាតបចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] ហ៊ុ តំណាងឱ្យឈ្មោះ[redacted]ហៀវ។

-លោក[redacted]តេក ជាមេធាវីបានធ្វើសេចក្តីសន្និដ្ឋានថា៖ យោងតាមមាត្រា៣៨៣ និង៤០៥ ជនជាប់ចោទបានធ្វើបណ្តឹងឧទ្ធរណ៍ ត្រូវបានហួសរយៈពេលកំណត់ នៃច្បាប់ហើយ។ ដូច្នេះស្នើសុំឱ្យតុលាការកំពូលសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាការពាររបស់ជនជាប់ចោទ និងសារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១២៣ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted]ឯម, បណ្តឹងសាទុក្ខលេខ១២៤ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ចេង និងបណ្តឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ឆាយ ធ្វើឡើងស្របតាមមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន។



Scanned by CamScanner

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ប្រកាសថាពាក្យបណ្ដឹងឧទ្ធរណ៍លេខ៣៦ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted]ឆាយ, ឈ្មោះ [redacted] ឯម និងឈ្មោះ [redacted]ង មិនអាចទទួលយកបាន តាមមាត្រា៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះ ជាការត្រឹមត្រូវ ហើយពីព្រោះថា សាលក្រមព្រហ្មទណ្ឌលេខ១១"ញ" ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ជាសាលក្រមចំពោះមុខ ហើយបណ្ដឹងឧទ្ធរណ៍បានធ្វើឡើងនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ ឃើញថាហួសរយៈពេលកំណត់០១ខែ ដែលមានចែងក្នុងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៦ក្រ.VI.ភស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ សម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ។

**ហេតុដូច្នេះ**

**សម្រេច**

១-បដិសេធបណ្ដឹងសាទុក្ខលេខ១២៣, ១២៤ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ឯម និងឈ្មោះ [redacted]ចេង និងបណ្ដឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted]ឆាយ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៦ក្រ.VI.ភស ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការ។

សាលដីកានេះ ជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted]ណ្ណ | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០១៦

បានឃើញ

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០១៦

ប្រធាន[illegible]ព្រហ្មទណ្ឌ

[redacted]

[redacted]